**សម្រាប់ទិវាអន្តរជាតិលុបបំបាត់ការរើសអើងពូជសាសន៍**
ថ្ងៃចន្ទ ទី២១ ខែមីនា ឆ្នាំ២០១៦

**"មានការរីកចម្រើនតិចតួចណាស់ ក្នុងការប្រយុទ្ធប្រឆាំងនឹងពូជសាសន៍និយម និងការស្អប់ខ្ពើមជនបរទេស នៅជុំវិញពិភពលោក"**

ទីក្រុងហ្សឺណែវ (១៧ មីនា ២០១៦) – ពិភពលោកកំពុងមើលឃើញការកើនឡើងគួរឲ្យព្រួយបារម្ភ មានជាពាក្យសំដីដែលខឹងនិងស្អប់ខ្ពើមជនបរទេស នេះបើតាមប្រសាសន៍របស់អ្នកជំនាញការបីរូបរបស់អង្គការសហប្រជាជាតិ ទទួលបន្ទុកពូជសាសន៍និយម និងការរើសអើង ថ្លែងនៅមុនទិវាអន្តរជាតិលុបបំបាត់ការរើសអើងពូជសាសន៍ ដែលប្រារព្ធឡើងនៅថ្ងៃចន្ទខាងមុខនេះ។

"មានកិច្ចការជាច្រើនទៀតដែលត្រូវធ្វើ ដោយរដ្ឋាភិបាលទាំងឡាយនៅជុំវិញពិភពលោក ដើម្បីការពារក្រុមងាយរងគ្រោះ និងផ្តន្ទាទោសជនល្មើស។ និទណ្ឌភាពបានក្លាយជាបទដ្ឋាន សម្រាប់អ្វីដែលជាបទល្មើសដ៏សាហាវយង់ឃ្នងនានា ហើយនេះគឺជាស្ថានភាពមួយគួរឲ្យព្រួយបារម្ភណាស់" នេះបើតាមប្រសាសន៍របស់អ្នករាយការណ៍ពិសេសស្តីពីទម្រង់សហសម័យនៃពូជសាសន៍និយម គឺ លោក **មុទុម៉ា រ៉ូតេ** (Mutuma Ruteere) ប្រធានអ្នករាយការណ៍នៃក្រុមការងារអ្នកជំនាញការទទួលបន្ទុកប្រជាជនដែលមានដើមកំណើតអាហ្វ្រិក គឺ លោកស្រី មីរេលលី ហ្វាណុង ម៉ង់ដេស ហ្វ្រង់សេ (Mireille Fanon Mendes-France) និងប្រធានគណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍ គឺ លោក ចូសេ ហ្វ្រង់ស៊ីស្កូ កាលី ហ្សាយ (José Francisco Cali Tzay)។

អ្នកជំនាញការសិទ្ធិមនុស្សបានមានប្រសានន៍ថា "ដប់ប្រាំឆ្នាំបន្ទាប់ពីមានសន្និសីទទីក្រុងឌូបាន ឃើញមានការរីកចម្រើនតិចតួចណាស់ ក្នុងការប្រយុទ្ធប្រឆាំងជាតិសាសន៍និយម ការស្អប់ខ្ពើមប្រជាជនដើមកំណើតអាហ្វ្រិក ការរើសអើងពូជសាសន៍ និងការមិនអត់ឱនដែលពាក់ព័ន្ធ"។

"ផ្ទុយទៅវិញ យើងឃើញមានការកើនឡើង គួរឲ្យព្រួយបារម្ភនៃពាក្យសំដីដែលខឹងនិងស្អប់ខ្ពើមជនបរទេស ដែលបន្ទរនៅទូទាំងពិភពលោក។ មេដឹកនាំនយោបាយ ឥស្សរជនសាធារណៈ និងសូម្បីតែប្រព័ន្ធផ្សព្វផ្សាយមហាជនក៏និយាយមិនល្អ និងទម្លាក់កំហុសឲ្យទេសសន្តរប្រវេសន៍ ជនភៀសខ្លួន ជនសុំសិទ្ធជ្រកកោន និងជនបរទេសជាទូទៅ ព្រមទាំងជនភាគតិចផងដែរ" អ្នកជំនាញការបានរំលឹកដូច្នេះ។

អ្នកជំនាញការបានសម្តែងកង្វល់ចំពោះការអំពាវនាវកាលពីពេលថ្មីៗនេះ ដោយអ្នកនយោបាយ និងមន្ត្រីផ្សេងៗ ឲ្យធ្វើការចាប់ខ្លួនក្រុមមនុស្ស និងឲ្យមានការនិរទេសជនបរទេស។ " ឥរិយាបថបែបនេះ ជម្រុញលើកទឹកចិត្តឲ្យមានអំពើហឹង្សាប្រឆាំងនឹងជនដែលងាយរងគ្រោះ" អ្នកជំនាញការបានត្អូញត្អែរដូច្នេះ។

ក្រុមអ្នកជំនាញការនេះ បានគូសបញ្ជាក់ផងដែរ អំពីការរាយការណ៍មិនពេញលេញអំពីសកម្មភាពប្រកាន់ពូជសាសន៍ និងការស្អប់ខ្ពើមជនបរទេស ដោយសង្កត់ធ្ងន់លើតម្រូវការឲ្យមានការពង្រឹងនូវការអនុវត្តច្បាប់ និងការឆ្លើយតបទៅនឹងយុត្តិធម៌ព្រហ្មទណ្ឌ។ ក្រុមអ្នកជំនាញការ បានផ្តល់អនុសាសន៍ផងដែរ ឲ្យមានការអប់រំអំពីសិទ្ធិមនុស្ស ដើម្បីផ្សព្វផ្សាយការយល់ដឹង និងការលើកកម្ពស់ការអត់ឱន។

"រដ្ឋទាំងឡាយ ត្រូវបំពេញការទទួលខុសត្រូវរបស់ខ្លួន ដូចដែលខ្លួនបានសន្យា ប្រឆាំងការស្អប់ខ្ពើមជនបរទេស ការស្អប់ខ្ពើមពូជសាសន៍ និងឲ្យមានការអត់ឱនដើម្បីបង្ការទប់ស្កាត់កម្រិតរាតត្បាត ក្នុងបរិបទពិភពលោក ដែលបច្ចុប្បន្ននេះ មានចលនាប្រជាជនទ្រង់ទ្រាយធំ ដែលធ្វើឲ្យភាពតានតឹងរិតតែធ្ងន់ធ្ងរឡើង" នេះបើតាមប្រសាសន៍របស់ក្រុមអ្នកជំនាញការ។

អ្នកជំនាញការ អ.ស.ប បានអំពាវនាវដល់រដ្ឋាភិបាលនានា ឲ្យបង្កើតផែនការសកម្មភាពសមស្រប ប្រឆាំងនឹងការរើសអើងពូជសាសន៍ ព្រមទាំងស្ថាប័នផ្សេងៗដែលមានសមភាព និងដើម្បីដោះស្រាយសំណងសមរម្យដល់ជនរងគ្រោះ។ ក្រុមអ្នកជំនាញការនេះ បានគូសបញ្ជាក់ផងដែរ ពីតម្រូវការឲ្យមានការប្រមូលទិន្នន័យដែលអាចទុកចិត្តបាន ដើម្បីឃ្លាំមើលស្ថានភាពប្រែប្រួល។

**ចប់**

***លោក មុទុម៉ា រ៉ូតេ*** *(Mr.* ***Mutuma Ruteere*** *) (កេនយ៉ា ) ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្សតែងតាំងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ជាអ្នករាយការណ៍ពិសេសស្តីពីទម្រង់សហសម័យនៃពូជសាសន៍និយម ការរើសអើងពូជសាសន៍ ការស្អប់ខ្ពើមជនបរទេស និងការមិនអត់ឱនដែលពាក់ព័ន្ធ។ ដើម្បីស្វែងយល់បន្ថែម សូមមើល៖* http://www.ohchr.org/EN/Issues/Racism/SRRacism/Pages/IndexSRRacism.aspx

*សម្រាប់ព័ត៌មានបន្ថែមនិង**ការស្នើសុំព័ត៌មាន** សូមទាក់ទងមក៖ យ៉ាយេ បា (Yaye Ba ) តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩២ ១០ ឬ អ៊ីម៉ែល* yba@ohchr.org*) ឬ ធារី ដែល ប្រាដូ (Thierry del Prado ) តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩២ ៣២ ឬ អ៊ីម៉ែល* tdelprado@ohchr.org*)*

*ក្រុមការងារនៃ អ្នកជំនាញការឯករាជ្យ ទទួលបន្ទុកប្រជាជនដែលដែលមានដើមកំណើតអាហ្វ្រិក ត្រូវបានអតីតគណៈកម្មការសិទ្ធិមនុស្សបង្កើតឡើងក្នុងឆ្នាំ២០០២ បន្ទាប់ពីមានសន្និសីទពិភពលោក ប្រឆាំងជាតិសាសន៍និយម ដែលបានធ្វើឡើងនៅទីក្រុង ក្រុងឌូបាន។*

*ដើម្បីស្វែងយល់បន្ថែម សូមមើល ៖*
*[http://www.ohchr.org/EN/Issues/Racism/WGAfricanDescent/Pages/WGEPADIndex.aspx](http://www.ohchr.org/EN/Issues/Racism/WGAfricanDescent/Pages/WGEPADIndex.aspx)*

*សំរាប់ព័ត៌មានបន្ថែមនិង**ការស្នើសុំព័ត៌មាន** សូមទាក់ទងមក គ្រីស្ទីនណា សោនឌឺរស៍ (Christina Saunder ) តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩២៨ ៩១៩៧ឬ អ៊ីម៉ែល csaunders@ohchr.org) ឬសរសេរទៅកាន់ africandescent@ohchr.org*

*គណៈកម្មាធិការទទួលបន្ទុក លុបបំបាត់ការរើសអើងពូជសាសន៍ (CERD ) គឺជាស្ថាប័នមួយនៃអ្នកជំនាញការឯករាជ្យ ដែល ឃ្លាំមើលការអនុវត្ត អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ដោយរដ្ឋទាំងឡាយដែលជាភាគីនៃអនុសញ្ញានេះ។ ដើម្បីស្វែងយល់បន្ថែម សូមមើល ៖ [http://www.ohchr.org/EN/HRBodies/CERD/Pages/CERDIndex.aspx](http://www.ohchr.org/EN/HRBodies/CERD/Pages/CERDIndex.aspx)*

*សម្រាប់ព័ត៌មានបន្ថែមនិង**ការស្នើសុំព័ត៌មាន** សូមទាក់ទងមក ហ្គាប្រីលឡា ហាបថូម (Gabriella Habtom ) តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩១៩៣ ឬ អ៊ីម៉ែល ghabtom@ohchr.org) ឬសរសេរទៅកាន់ cerd@ohchr.org*

សំរាប់**ការសាកសួរព័ត៌មាន**ពាក់ព័ន្ធនឹងអ្នកជំនាញការឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមទាក់ទងមក៖ ហ្សាបៀរ សែឡាយ៉ា ( Xabier Celaya ) – អង្គភាពប្រព័ន្ធផ្សព្វផ្សាយ តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣៨៣ / អ៊ីម៉ែល xcelaya@ohchr.org)

**សម្រាប់វិបសាយព័ត៌មានរបស់លោក/អ្នក និងបណ្តាញសង្គម៖** មាតិកាពហុប្រព័ន្ធផ្សព្វផ្សាយ និងសារគន្លឹះៗទាក់ទងនឹងប្រកាសព័ត៌មានរបស់យើង អាចរកបាននៅលើឆាណែលបណ្តាញសង្គមសិទ្ធិមនុស្ស អ.ស.ប ដែលមានរាយឈ្មោះខាងក្រោមនេះ។ សូមថេក (t a g ) មកយើង ដោយប្រើចំណុចបើកត្រឹមត្រូវ៖

ទ្វីតធឺ៖ @UNHumanRights

ហ្វេសប៊ុក៖ unitednationshumanrights

Instagram: unitednationshumanrights

ហ្គោហ្គីល៖ Google+: unitednationshumanrights
យូធូប៖ unohchr